01057573

E330/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 01 / 2015
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥

**ផ្ញើជូន៖** អគ្គរដ្ឋអាជ្ញាសាលាឧទ្ធរណ៍ក្រុងប៉ារីស
ប្រធានគណៈមេធាវីក្រុងប៉ារីស

**ពី៖** ចៅក្រម និល ណុន
ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
ភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២

**កម្មវត្ថុ៖** ការបញ្ជូនបន្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ចំណោះដើង "ដីកាបញ្ជូនការប្រព្រឹត្តិរបស់មេធាវីការពារក្តី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ច"

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") គឺជាតុលាការមួយដែលបង្កើតឡើងដោយអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបខ្មែរក្រហម។ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បច្ចុប្បន្ននេះបានទទួលសំណុំរឿង ០០២ រួមមាន លោក ខៀវ សំផន ដែលត្រូវបានចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ខ្ញុំសូមភ្ជាប់ជូននូវឯកសារក្របខ័ណ្ឌនៃ អ.វ.ត.ក ដូចមានខាងក្រោមសម្រាប់ជាឯកសារយោង៖

- ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក៖ http://www.eccc.gov.kh/sites/default/files/legal-documents/KR_Law_as_amended_27_Oct_2004_Eng.pdf

- វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក៖ http://www.eccc.gov.kh/en/document/legal/internal-rules-rev8

លោកArthur VERCKEN និងអ្នកស្រីAnta GUISSÉ ទាំងពីរនាក់ ជាសមាជិកនៃគណៈមេធាវីក្រុងប៉ារីស គឺជាមេធាវីតំណាង លោក ខៀវ សំផន នៅក្នុងសំណុំរឿង ០០២។ សំណុំរឿង ០០២ ត្រូវបានបំបែកទៅជាការជំនុំជម្រះពីរផ្នែកដាច់ដោយឡែកពីគ្នា ដោយផ្នែកនីមួយៗដោះស្រាយផ្នែកផ្សេងៗនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការជំនុំជម្រះផ្នែកទីមួយ គឺសំណុំរឿង ០០២/០១ បានបញ្ចប់រួចហើយ ហើយបានចេញសាលក្រមប្រឆាំងលោក ខៀវ សំផន និងសហជនចាប់ចោទរបស់គាត់ គឺលោក នួន ជា កាលពីថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤។ ព័ត៌មានបន្ថែមទៀតអំពីសំណុំរឿង ០០២ អាចមាននៅក្នុងឯកសារដូចខាងក្រោម៖

- ដីកាដំណោះស្រាយសំណុំរឿង ០០២៖ http://www.eccc.gov.kh/sites/default/files/documents/courtdoc/D427Eng.pdf
- សាលក្រមសំណុំរឿង ០០២/០១៖ http://www.eccc.gov.kh/en/document/court/case-00201-judgement

សវនាការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/២ បានគ្រោងចាប់ផ្តើមធ្វើឡើងនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ។ នៅថ្ងៃនោះ មេធាវីការពារក្តី ខៀវ សំផន បានបង្ហាញថា ពួកគាត់មិនមានបំណងចូលរួមកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ ទេ រហូតទាល់តែពួកគាត់បានដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ រួចសិន ។ បន្ទាប់មក មេធាវីការពារក្តីបានចាកចេញពីសាលសវនាការ ក្រោយមក អង្គជំនុំជម្រះបានផ្អាកដំណើរការនីតិវិធី។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលតាមជនជាប់ចោទ និងមានការបង្គាប់យ៉ាងច្បាស់លាស់ឱ្យមេធាវីរបស់ជនជាប់ចោទចូលរួមក្នុងតុលាការក៏ដោយ ក៏អង្គជំនុំជម្រះ នៅតែជួបប្រទះបញ្ហាការបដិសេធមិនព្រមចូលរួមកិច្ចដំណើរការនីតិវិធី និងកង្វះកិច្ចសហការពីមេធាវីការពារក្តី ដែលបញ្ហានេះបានបង្ខំឱ្យអង្គជំនុំជម្រះ ផ្អាកកិច្ចដំណើរការនីតិវិធីរហូតដល់ខែ មករា ឆ្នាំ ២០១៥ ។ ដើម្បីចៀសវាងកុំឱ្យមានស្ថានភាពនេះកើតឡើងម្តងទៀតនាពេលអនាគត អង្គជំនុំជម្រះបានតែងតាំងមេធាវីប្រចាំការជាតិម្នាក់ និងអន្តរជាតិម្នាក់ដែលចាត់តាំងដោយតុលាការដើម្បីតំណាង ខៀវ សំផន[1]។

[1]សេចក្តីសម្រេចស្តីអំពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ខៀវ សំផន ឯកសារ E321/2 ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤។

នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានសម្រេចថា ការរំលោភបំពានរបស់មេធាវីការពារក្ដី ខៀវ សំផន ទៅលើដីកាតុលាការឱ្យចូលរួមសវនាការដែលបានគ្រោងទុក បានធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីដែលតម្រូវឱ្យមានការដាក់ទណ្ឌកម្ម អនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក[2]។ រហូតមកដល់ពេលនេះ ការបដិសេធរបស់មេធាវីការពារក្ដីមិនចូលរួមសវនាការរបស់តុលាការ បានធ្វើឱ្យបាត់បង់សវនាការចំនួន ២៥ ថ្ងៃ ក្នុងរយៈពេល ១០ សប្ដាហ៍។ អង្គជំនុំជម្រះ បានដោះស្រាយ ហើយនឹងបន្តដោះស្រាយកំហុសវិជ្ជាជីវៈនេះតាមវិធានផ្ទៃក្នុងរបស់ខ្លួន ប៉ុន្តែដោយពិនិត្យថា ការប្រព្រឹត្តិរបស់មេធាវីទាំងនេះនៅក្នុងប្រទេសកម្ពុជា ក៏អាចបណ្ដាលឱ្យមានបញ្ហានានាទាក់ទិននឹងសមត្ថភាពវិជ្ជាជីវៈរបស់ពួកគាត់ និងការគោរពតាមភារកិច្ចក្រមសីលធម៌តាមវិធានដែលអាចអនុវត្តទៅលើមេធាវីបារាំងនោះ អង្គជំនុំជម្រះបានសម្រេចបញ្ជូនបញ្ហានេះទៅប្រធានគណៈមេធាវីក្រុងប៉ារីស និងរដ្ឋអាជ្ញាសាលាឧទ្ធរណ៍ក្រុងប៉ារីស ដើម្បីឱ្យក្រុមប្រឹក្សាវិន័យជាប់ពាក់ព័ន្ធ ចាត់វិធានការ។ តាមសំអាងហេតុទាំងនេះ សូមភ្ជាប់ជូននៅក្នុងលិខិតនេះនូវសេចក្ដីសម្រេចនាពេលថ្មីៗរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ ព្រមទាំង បញ្ជីព័ត៌មាន ស្ដីពីសេចក្ដីសម្រេចពាក់ព័ន្ធបន្ថែមទៀតសម្រាប់ជាការពិចារណា ដើម្បីឱ្យលោកអាចចាត់វិធានការដែលលោកគិតថាសមស្រប។ អាស្រ័យហេតុនេះ ខ្ញុំសូមអរគុណ ប្រសិនបើលោកជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូង តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះក្នុងពេលវេលាសមស្រប អំពីលទ្ធផលនៃការបញ្ជូនកំហុសវិជ្ជាជីវៈ និងការចាត់វិធានការណាមួយទៅលើកំហុសវិជ្ជាជីវៈនេះ ។

ប្រសិនបើលោកមានសំណួរ ឬ ត្រូវការនូវព័ត៌បន្ថែមទៀតពីអង្គជំនុំជម្រះ សូមផ្ញើសំណួរមក៖

លោក Ken Roberts (roberts13@un.org)

មន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ប្រអប់សំបុត្រ ៧១ ភ្នំពេញ ប្រទេសកម្ពុជា

[2]ដីកាបញ្ជូនការប្រព្រឹត្តិរបស់មេធាវីការពារក្ដី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ច ឯកសារ E330 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ២៩-៣១។

# បញ្ជីព័ត៌មានស្តីពីសេចក្តីសម្រេចពាក់ព័ន្ធបន្ថែមទៀតរបស់ អ.វ.ត.ក

- អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចំណងជើង "ការព្រមានមេធាវីការពារក្តី នួន ជា និង ខៀវ សំផន" ឯកសារ E320 ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ អាចចូលពិនិត្យមើលបានតាមរយៈ៖ http://www.eccc.gov.kh/en/document/court/trial-chamber-memorandum-entitled-%E2%80%9Cwarning-counsel-nuon-chea-and-khieu-samphan%E2%80%9D

- អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចំណងជើង "សេចក្តីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤" ឯកសារ E320/1 ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ អាចចូលពិនិត្យមើលបានតាមរយៈ៖ http://www.eccc.gov.kh/en/document/court/ruling-following-tmm-28-october-2014

- សេចក្តីសម្រេចលើការតែងតាំងមេធាវីដែលចាត់តាំងដោយតុលាការសម្រាប់ខៀវ សំផន ឯកសារ E320/2 ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ អាចចូលពិនិត្យមើលបានតាមរយៈ៖ http://www.eccc.gov.kh/sites/default/files/documents/courtdoc/2014-11-21%2015:00/E320_2_EN.PDF

- សេចក្តីសម្រេចស្តីអំពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ខៀវ សំផន ឯកសារ E321/2 ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ អាចចូលពិនិត្យមើលបានតាមរយៈ៖ http://www.eccc.gov.kh/en/document/court/TC-5-December-2014